**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ ០៧៩ ស.ជ.ណ

# សេចក្ដីជូនដំណឹង
# ស្ដីពី មហាសន្និបាតភាគហ៊ុនិក លើកទី៩
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ជ្រាបថា៖ រ.ទ.ស.ភ នឹងរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី៩ **នៅថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥** ត្រូវនឹង **ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១** ចាប់ពីម៉ោង **០៨:០០នាទីព្រឹក** តាមប្រព័ន្ធអនឡាញ (ZOOM) ដែលមានរបៀបវារៈដូចខាងក្រោម៖

១. ការចុះវត្តមាន

២. ប្រកាសហេតុ

៣. បទបង្ហាញស្ដីពី៖

- ក- របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២០
- ខ- ទិសដៅអាជីវកម្ម ឆ្នាំ២០២១
- គ- សំណួរ-ចម្លើយ

៤. កម្មវិធីបោះឆ្នោត

- ក- បោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក
- ខ- បោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល

៥. មតិបូកសរុបរបស់ប្រធានគណៈអធិបតី

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ (កាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក លើកទី៩) ត្រូវបញ្ជាក់ការចូលរួមជាមួយ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) នៅរៀងរាល់ថ្ងៃធ្វើការ **ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១** ដល់ **ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១** ចាប់ពីម៉ោង **០៨:០០នាទី** ដល់ម៉ោង **១៦:៣០នាទី**។

**បញ្ជាក់៖**

**១.** ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់រ.ទ.ស.ភ ប៉ុន្តែមិនបានធ្វើការបញ្ជាក់ការចូលរួមរបស់ខ្លួនជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើនេះ នឹងមិនអនុញ្ញាតឱ្យចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ រ.ទ.ស.ភ ទេ។

**២.** ភាគហ៊ុនិកអាចចូលរួមមហាសន្និបាតនេះ ដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ(អ្នកតំណាង)។ ភាគហ៊ុនិកដែលចូលរួមតាមរយៈអាណត្តិគាហកៈ ត្រូវតែងតាំងអាណត្តិគាហកៈរបស់ខ្លួនទៅតាមទម្រង់ "លិខិតតែងតាំងអាណត្តិគាហកៈ(អ្នកតំណាង)" ដែលផ្ដល់ដោយ រ.ទ.ស.ភ ឬ ធនាគារ អេស៊ីលីដា ភីអិលស៊ី និង**ត្រូវផ្ដល់លិខិតតែងតាំងអាណត្តិគាហកៈនេះជូន រ.ទ.ស.ភ តាមរយៈសារអេឡិចត្រូនិក** ir@ppwsa.com.kh **ឱ្យបានមុនថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១** ដើម្បីចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ រ.ទ.ស.ភ។



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

៣. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមរក្សាសិទ្ធិកែប្រែកម្មវិធី របៀបវារៈ និងទម្រង់អនឡាញនៃមហាសន្និបាតភាគហ៊ុនិក លើកទី៩ ក្នុងករណីមានការចាំបាច់។

ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ ធនាគារ អេស៊ីលីដា ភីអិលស៊ី និង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

- **ធនាគារ អេស៊ីលីដា ភីអិលស៊ី**

  អាសយដ្ឋាន: អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

  - **លោក លឹម អាន** ប្រធានផ្នែកជាន់ខ្ពស់ប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥)១៥ ៦០០ ៧៤៣ / ៧៧ ៥៦៧ ៩៣៥ (បន្តទៅលេខ 05013)
    អ៊ីម៉ែល: lim.an@acledabank.com.kh
    lim.phengan@gmail.com
  - **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥)១៥ ៩០០ ៥៣៨ (បន្តទៅលេខ 05020)
    អ៊ីម៉ែល: huot.sophy@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណិបុប្ផារង្ស** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥)៨១ ៦៨៦ ៩៨៨ / ៦១ ២៨៧ ៧៦៦ (បន្តទៅលេខ 05020)
    អ៊ីម៉ែល: op.rtp@acledabank.com.kh

- **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
  - អាសយដ្ឋាន : លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ទូរស័ព្ទដៃ : (៨៥៥)៣១ ៣ ២២ ៦៣ ៤៥
  - អ៊ីម៉ែល : ir@ppwsa.com.kh

ថ្ងៃពុធ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១
**ជ.គណៈកម្មការរៀបចំ និងដំណើរការ**
**មហាសន្និបាតភាគហ៊ុនិក លើកទី៩**
**ប្រធាន**

**ស៊ឹម ស៊ីថា**

**ចម្លងជូន៖**
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យរដ្ឋ រ.ទ.ស.ភ

"*មេត្តាជ្រាប*"

- ឯកសារ-កាលប្បវត្តិ។